**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីជូនព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូល
# រំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ឥណ្ឌា និងពិធីអបអរទិវាសាធារណរដ្ឋលើកទី៦៩
# ថ្ងៃទី ២៥-២៦ ខែមករា ឆ្នាំ២០១៨ សាធារណរដ្ឋឥណ្ឌា

--------------------------------

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាន ដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ឥណ្ឌា និងពិធីអបអរសាទរទិវាសាធារណរដ្ឋលើកទី៦៩ នៅទីក្រុងញូវដែល្លី សាធារណរដ្ឋឥណ្ឌា ដែលបានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៨ តបតាមការអញ្ជើញរបស់ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋឥណ្ឌា។

កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ឥណ្ឌា ក្រោមមូលបទ “តម្លៃរួម ជោគវាសនារួម” បានប្រព្រឹត្តឡើង ស្របពេលដែលទំនាក់ទំនងដៃគូអាស៊ាន-ឥណ្ឌាបានគំរប់ខួបទី២៥ឆ្នាំ ប្រកបដោយភាពកក់ក្តៅ។

ចំពោះដំណើរការកសាងសហគមន៍អាស៊ាន ថ្នាក់ដឹកនាំបានតាំងចិត្តបង្កើនកិច្ចខិតខំប្រឹងប្រែងឡើងថែមទៀត និងធ្វើកិច្ចសហប្រតិបត្តិការឆ្ពោះទៅការអនុវត្តឲ្យបានទាំងពេញលេញ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលានូវផែនការសកម្មភាព ដើម្បីអនុវត្តភាពជាដៃគូអាស៊ាន-ឥណ្ឌា សម្រាប់សន្តិភាព វឌ្ឍនភាព និងវិបុលភាពរួម (២០១៦-២០២០) និងបន្តគាំទ្រដល់សមាហរណកម្មអាស៊ាន និងការសម្រេចឲ្យបាននូវទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥។

ក្នុងកិច្ចប្រជុំកំពូលនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកឡើងនូវចំណុចសំខាន់ៗ ដូចខាងក្រោម៖

**ទីមួយ**) គាំទ្រវិស័យអាទិភាពក្រោមផែនការសកម្មភាពថ្មីអាស៊ាន-ឥណ្ឌា សម្រាប់អនុវត្តពីឆ្នាំ ២០១៦-២០១៨ ដូចជា (១) សម្រេចទិសដៅពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា ២០០ប៊ីលានដុល្លារអាមេរិក ត្រឹមឆ្នាំ២០២២ (២) ប្រើប្រាស់ឥណទាន ១ប៊ីលានដុល្លារអាមេរិក ដែលបានផ្តល់ដោយឥណ្ឌាឲ្យបាន ទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីគាំទ្រការអនុវត្តការតភ្ជាប់រូបវ័ន្ត និងឌីជីថល (៣) គាំទ្រអាស៊ាន

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

តាមរយៈការលើកកម្ពស់សមត្ថភាពក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ទំនាក់ទំនងបច្ចេកវិទ្យាអវកាស និងការស្រាវជ្រាវ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

**ទីពីរ**) លើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងការវិនិយោគឲ្យកាន់តែជិតស្និទ្ធ តាមរយៈ (១) ពង្រឹងការបង្កើតសហគ្រាសធុនតូច និងមធ្យម និងការប្រកួតប្រជែង ដោយផ្តោតលើការលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងសហគ្រិនវ័យក្មេង នៅតាមបណ្តាប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (២) លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យនវានុវត្តន៍ (៣) ពិនិត្យលទ្ធភាពជំរុញកិច្ចសហប្រតិបត្តិការ ក្នុងវិស័យឧស្សាហកម្មថ្មី និង (៤) ប្រើប្រាស់មជ្ឈមណ្ឌលពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-ឥណ្ឌាឲ្យកាន់តែមានប្រសិទ្ធភាព។

**ទីបី**)កម្ពុជាសូមស្នើឲ្យទាំងអាស៊ាន និងឥណ្ឌា បញ្ចប់ការចរចាស្របតាមពេលវេលាដូចបានកំណត់ ដែលភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់នឹងក្លាយជាកម្លាំងចលករជួយជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារថ្មី ធ្វើឲ្យកាន់តែស៊ីជម្រៅនូវខ្សែសង្វាក់ផ្គត់ផ្គង់ និង តម្លៃបន្ថែមក្នុងតំបន់ (Regional Supply Chain and Value added) ជួយធ្វើឲ្យប្រសើរឡើងនូវជីវភាព រស់នៅរបស់ប្រជាជន និងប្រែក្លាយតំបន់នៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ឲ្យទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេដ្ឋកិច្ចបែបថ្មីមួយ សម្រាប់ជួយទ្រទ្រង់ដល់កំណើននៃសេដ្ឋកិច្ចសាកលលោក។

**ទីបួន**) បន្តកិច្ចសហប្រតិបត្តិការថែមទៀតក្នុងវិស័យអប់រំ តាមរយៈការផ្តល់អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលដល់សិស្ស និស្សិត ទំនាក់ទំនងប្រជាជននិងប្រជាជន ក៏ដូចជា ការគាំទ្រដល់ការអនុវត្តផែនការទី៣ នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។

**ទីប្រាំ**) ដោយសារឥណ្ឌាជាប្រទេសដែលមានព្រំប្រទល់ជាប់ជាមួយអាស៊ាន ឥណ្ឌាមានតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចឲ្យបាននូវការតភ្ជាប់ផ្លូវហាយវេត្រីភាគី ឥណ្ឌា-មីយ៉ាន់ម៉ា-ថៃ និងការតភ្ជាប់ដល់ឡាវ និងកម្ពុជា និងការបង្កើតផ្លូវហាយវេមួយទៀត ភ្ជាប់ពីឥណ្ឌា-ឡាវ-វៀតណាម-កម្ពុជា។

**ទីប្រាំមួយ**) មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីនដែលមានទីស្នាក់ការនៅកម្ពុជា ត្រូវបានសម្ពោធជាផ្លូវការនៅខែឧសភា ឆ្នាំ២០១៦។ នាយកប្រតិបត្តិបានចូលបម្រើការងារជាផ្លូវការនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧។ កម្ពុជាស្នើឥណ្ឌាពិចារណាផ្តល់ការគាំទ្រដល់មជ្ឈមណ្ឌលនេះ តាមរយៈជំនួយហិរញ្ញវត្ថុ និងសម្ភារបច្ចេកទេសនានា ដើម្បីរួមចំណែកដល់ការដាក់ឲ្យដំណើរការរបស់មជ្ឈមណ្ឌលនេះឲ្យមានប្រសិទ្ធភាពសម្រាប់ជាប្រយោជន៍ដល់អាស៊ាន និងតំបន់ទាំងមូល។

កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ បានបញ្ជាក់សាជាថ្មីអំពីសារសំខាន់នៃការថែរក្សា និងការលើកកម្ពស់សន្តិភាព ស្ថិរភាព សុវត្ថិភាព និងសន្តិសុខលំហសមុទ្រ សេរីភាពនៃការធ្វើនាវាចរ និងការហោះហើរនៅក្នុងតំបន់ និងការលើកកម្ពស់ដំណោះស្រាយជម្លោះដោយសន្តិវិធី ស្របតាមគោលការណ៍ទទួលស្គាល់ជាសាកលនៃច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២ (UNCLOS) និងច្បាប់អន្តរជាតិពាក់ព័ន្ធដទៃទៀត។

ថ្នាក់ដឹកនាំបានយល់ព្រមពង្រឹងកិច្ចសហប្រតិបត្តិការសមុទ្រ ការប្រយុទ្ធប្រឆាំងភេរវកម្មគ្រប់ទំរង់ និងរូបភាព អំពើហិង្សាជ្រុលនិយម និងរ៉ាឌីកាល់និយម តាមរយៈការចែករំលែកព័ត៌មាន ការពង្រឹងការអនុវត្តច្បាប់ និងការកសាងសមត្ថភាព ក៏ដូចជាការកសាងសមត្ថភាពសន្តិសុខតាមប្រព័ន្ធអ៊ីនធើណេត និងការសម្របសម្រួលគោលនយោបាយ។

កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ក៏បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន-ឥណ្ឌាបន្ថែមទៀត ព្រមទាំងរំពឹងរង់ចាំការបញ្ចប់ឲ្យបានឆាប់នូវភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) គ្រប់ជ្រុងជ្រោយ ជំរុញថែមទៀតនូវសហគ្រាសមីក្រូ តូច និងមធ្យម ពង្រឹងសន្តិសុខស្បៀង និងថាមពលរយៈពេលយូរ នៅក្នុងតំបន់ ការលើកកំពស់វិស័យឯកជន និងពង្រឹងទំនាក់ទំនងធុរកិច្ច ព្រមទាំងរំពឹងដល់ការបង្កើតមជ្ឈមណ្ឌលវិនិយោគ និងពាណិជ្ជកម្មអាស៊ាន-ឥណ្ឌា។

ថ្នាក់ដឹកនាំក៏បានយល់ព្រមដល់ការពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន-ឥណ្ឌា ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ រួមមាន ការគាំទ្រដល់ការងាររបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់សម្របសម្រួលជំនួយមនុស្សធម៌លើការគ្រប់គ្រងគ្រោះមហន្តរាយ (AHA Centre) ដើម្បីសម្រេចឲ្យបាននូវសេចក្តីថ្លែងការណ៍របស់អាស៊ានស្តីពី "អាស៊ានមួយ ការឆ្លើយតបតែមួយ" ព្រមទាំងបង្កើតភាពជាដៃគូយ៉ាងជិតស្និទ្ធរវាង AHA Centre និងដៃគូឥណ្ឌា ដើម្បីធ្វើឲ្យកាន់តែល្អប្រសើរឡើង ការសម្របសម្រួលលើការគ្រប់គ្រងគ្រោះមហន្តរាយក្នុងតំបន់។

នៅក្នុងឱកាសបិទកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ ប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ាន ឥណ្ឌា បាន អនុម័តសេចក្តីថ្លែងការណ៍ទីក្រុងដេលី្ល។

ក្រៅពីការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍ សម្តេចតេជោនាយករដ្ឋមន្ត្រី បាន អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងទិវាសាធារណរដ្ឋលើកទី៦៩ អញ្ជើញពិសារអាហារពេលព្រឹកការងារជាមួយឯកឧត្តម ង្វៀន សួនហ៊្វុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងអញ្ជើញទស្សនកិច្ចក្រសួងអេឡិចត្រូនិច និងបច្ចេកវិទ្យាព័ត៌មាន ផងដែរ។

ថ្ងៃអាទិត្យ ១២កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៨